ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្ដាល

THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ១៨២/១៣-នីច-ធី អ៊ីតេរីល

កាលបរិច្ឆេទនៃសេចក្ដីបង្គាប់ ៖ ថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ ២០១៣

# សេចក្ដីបង្គាប់អាជ្ញាកណ្ដាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្ដីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្ដាល

អាជ្ញាកណ្ដាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ **កៅ ថាច**

អាជ្ញាកណ្ដាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ **អន ណន**

ប្រធានក្រុមអាជ្ញាកណ្ដាលជ្រើសរើសឡើងដោយអាជ្ញាកណ្ដាលទាំងពីរខាងលើ ៖ **គង់ ផល្លះ**

## ភាគីនៃវិវាទ

### ១- ភាគីនិយោជក

ឈ្មោះ ៖ **ក្រុមហ៊ុន នីច-ធី អ៊ីតេរីល (ខេមបូឌា)**

អាសយដ្ឋាន ៖ ភូមិម៉ល សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០៨៥ ៣៣០ ៧៧ ទូរសារ ៖ គ្មាន

តំណាងភាគីនិយោជក ៖

- លោក កាន់ សុវណ្ណឌី ប្រធានរដ្ឋបាល

### ២- ភាគីកម្មករនិយោជិត

ឈ្មោះ ៖ - **សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា**

អាសយដ្ឋាន ៖ ផ្ទះលេខ២-៣G ផ្លូវលេខ២២៦BT សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០១២ ៥០៤ ១៥៤ ទូរសារ ៖ គ្មាន

តំណាងកម្មករនិយោជិត ៖

- លោក ស៊ាង យ៉ូត មន្ត្រីច្បាប់សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- ទាមទារឱ្យក្រុមហ៊ុនកាត់ប្រាក់រង្វាន់ធ្វើការទៀងទាត់ តាមសមាមាត្រចំនួនថ្ងៃ ដែលកម្មករឈប់សម្រាក មានច្បាប់ ។

២- ទាមទារឱ្យក្រុមហ៊ុនបញ្ឈប់ការកំណត់ចំនួនផលិតផលលើសពីកំលាំងកម្មករ ។

៣- ទាមទារឱ្យក្រុមហ៊ុនផ្តល់ភាពងាយស្រួលក្នុងការសុំច្បាប់ ។

៤- ទាមទារឱ្យក្រុមហ៊ុនផ្តល់ប្រាក់ថ្លៃបាយថ្ងៃត្រង់ ចំនួន ៤០០០ រៀល ក្នុងមួយពេល ។

៥- ទាមទារឱ្យក្រុមហ៊ុនបន្តកិច្ចសន្យាការងារជូនកម្មករចំនួន ១ ឆ្នាំម្តង ។

៦- ទាមទារឱ្យក្រុមហ៊ុនដកអ្នកគ្រប់គ្រងចិនចេញពីក្រុមហ៊ុន នីច ធី ។

៧- ទាមទារឱ្យក្រុមហ៊ុនអនុវត្តន៍ការថែមម៉ោងតាមគោលការណ៍ស្ម័គ្រចិត្ត ។

៨- ទាមទារឱ្យក្រុមហ៊ុនជួយសម្រួលកន្លែងកម្មករធ្វើការឱ្យបានត្រជាក់សមរម្យ ។

៩- ទាមទារឱ្យក្រុមហ៊ុនបញ្ចូលកិច្ចសន្យាការងារកម្មករបុរស ចាប់ពី ៣ ខែ នៅពេលកម្មករពេញសិទ្ធិ ។

១០- ទាមទារឱ្យក្រុមហ៊ុនបញ្ឈប់ការកាត់ប្រាក់ឈ្នួលរបស់កម្មករបង់ចូលភាគទានសហជីព ដែលគ្មានការយល់ព្រមពីកម្មករនិយោជិត ។

១១- ទាមទារឱ្យក្រុមហ៊ុនរក្សាប្រាក់ឈ្នួល និងប្រាក់រង្វាន់ធ្វើការទៀងទាត់ អំឡុងពេលកម្មករធ្វើកូដកម្ម និងមិនគុំគួនកម្មករធ្វើកូដកម្មណាម្នាក់ឡើយ ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១២១ កប/ប្រក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១២ (អាណត្តិទី១០) ។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី២ (ក) នៃច្បាប់ស្តីពីការងារ ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជាលេខ ១០៦៤ កប/អក/វក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៣ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៣ ។

## សង្ខេបនីតិវិធី

**បញ្ហានៃនីតិវិធី ៖**

នៅថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៣ នាយកដ្ឋានវិវាទការងារ បានទទួលបណ្តឹងតាមទូរស័ព្ទពីសម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា ស្តីពីកម្មករនិយោជិតធ្វើកូដកម្មទាមទារឱ្យក្រុមហ៊ុនកែលំអនូវលក្ខខណ្ឌការងារមួយចំនួនឱ្យបានល្អប្រសើរ ។ បន្ទាប់ពីបានទទួលបណ្តឹងនេះមក នាយកដ្ឋានវិវាទការងារ បានចាត់មន្ត្រីជំនាញឱ្យធ្វើការដោះស្រាយវិវាទការងារនេះ ជាបន្តបន្ទាប់ និងផ្សះផ្សាជាលើកចុងក្រោយ នៅថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៣

ដោយទទួលបានលទ្ធផលមិនសះជានឹងគ្នាចំនួន ១១ ចំណុច លើការទាមទារចំនួន ១១ ចំណុច។ ចំណុចមិនសះជាចំនួន ១១ ចំណុចនេះ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២៧ ខែសីហា ឆ្នាំ ២០១៣ តាមរយៈរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួម លេខ ១០៦៤ ក.ប/អក/វក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៣។

បន្ទាប់ពីបានទទួលសំណុំរឿងនេះមក ក្រុមអាជ្ញាកណ្តាលត្រូវបានបង្កើតឡើងនៅថ្ងៃទី២៨ ខែសីហា ឆ្នាំ ២០១៣ ហើយលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល បានកោះអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិត មកសវនាការ និងធ្វើការផ្សះផ្សាលើចំណុចមិនសះជាចំនួន ១១ ចំណុចនេះ នៅថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៣ វេលាម៉ោង ៨៖៣០ នាទី ព្រឹក។

ប៉ុន្តែ នៅថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១៣ នាយកក្រុមហ៊ុន នីច ធី អឹរែភែរីល បានធ្វើលិខិតសំណើមួយច្បាប់មកក្រុមប្រឹក្សាអាជ្ញាកណ្តាល ដើម្បីសុំឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលចេញសេចក្តីបញ្ជា ដើម្បីផ្អាកការធ្វើកូដកម្មរបស់កម្មករ និយោជិត នៅក្រុមហ៊ុន នីច ធី អឹរែភែរីល។ **ក្រោយពីបានទទួលព័ត៌មាននេះ លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល បានទំនាក់ទំនងទៅភាគីកម្មករនិយោជិត ក៏បានទទួលព័ត៌មានថា មានកូដកម្មកើតឡើងមែន។**

ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចេញសេចក្តីបញ្ជាលេខ ០៣៥/១៣ កបអ. ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ ២០១៣ ដើម្បីបញ្ជាឱ្យកម្មករនិយោជិតដែលទាមទារនៅក្នុងសំណុំរឿងនេះ ផ្អាកជាបន្ទាន់ នូវការធ្វើកូដកម្ម រហូតដល់នីតិវិធីនៃអាជ្ញាកណ្តាល ត្រូវបានបញ្ចប់សព្វគ្រប់តាមនីតិវិធីច្បាប់ ហើយកូដករទាំងអស់ត្រូវត្រឡប់ចូលធ្វើការវិញ ចាប់ពីព្រឹកថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១៣ តទៅ ទៅតាមវេនរបស់ខ្លួន ប៉ុន្តែ កម្មករនិយោជិតមិនបានគោរពតាមសេចក្តីបញ្ជារបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនោះទេ។

តាមរយៈរបាយការណ៍របស់ភាគីនិយោជក **ដែលទាក់ទងនឹង**ស្ថានភាពកូដកម្ម នៅក្រុមហ៊ុន នីច ធី អឹរែភែរីល ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៣ ដែលដាក់ជូនក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៣ និងការបញ្ជាក់ដោយផ្ទាល់មាត់ពីសំណាក់ភាគីកម្មករនិយោជិត**តាមរយៈទូរស័ព្ទនៅថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១៣** បានឱ្យដឹងថា នៅថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១៣ កូដកម្មនៅតែបន្តនៅក្រុមហ៊ុន នីច ធី អឹរែភែរីល ដដែល ទោះបីជាមានសេចក្តីបញ្ជារបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ឱ្យកូដករទាំងអស់បញ្ឈប់ការធ្វើកូដកម្ម និងត្រឡប់ចូលធ្វើការវិញក៏ដោយ។ លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានផ្ញើលិខិតមួយច្បាប់ **លេខ ៩៤៨ កប/អក/វក ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ ២០១៣** ជូនដល់ប្រធានសម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា ដើម្បីឱ្យភាគីកម្មករ និយោជិតផ្តល់របាយការណ៍ ទាក់ទងនឹងស្ថានភាពបច្ចុប្បន្ននៃកូដកម្ម នៅក្រុមហ៊ុន នីចធី អឹរែភែរីល មកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល យ៉ាងយូរត្រឹមថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៣ វេលាម៉ោង ១១៖៣០ នាទី ព្រឹក ជាកំហិត។ ភាគីកម្មករនិយោជិតមិនបានដាក់របាយការណ៍នេះ មកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល តាមកាលកំណត់ទេ។ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាករណីនេះ ដូចខាងក្រោម ៖

**ភស្តុតាង**

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

**ឯកសារ ឧត្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

**ក- ឯកសារបានទទួលពីភាគីនិយោជក ៖**

១- លិខិតរបស់ក្រុមហ៊ុន នីច ធី អីភែរីល គោរពជូន ក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីសំណើសុំចេញសេចក្តីបញ្ជា ដើម្បីផ្អាកការធ្វើកូដកម្មរបស់កម្មករនិយោជិតនៅក្រុមហ៊ុន នីច ធី អីភែរីល ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១៣។

២- លិខិតផ្ទេរសិទ្ធិ របស់នាយកក្រុមហ៊ុន នីច ធី អីភែរីល (ខេមបូឌា) ខូអិលធីឌី គោរពជូន លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីសំណើសុំផ្ទេរសិទ្ធិជូន លោក កាន់ សុវណ្ណឌី ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៣។

៣- សារណាសង្ខេបនៃវិវាទរបស់ក្រុមហ៊ុន នីច ធី អីភែរីល ខូអិលធីឌី ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៣។

៤- ឯកសាររូបភាព ស្តីពីសកម្មភាពកូដករ ថ្ងៃទី៣-៤ ខែកញ្ញា ឆ្នាំ២០១៣

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖ គ្មាន**

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន នីច ធី អីភែរីល (ខេមបូឌា) ខូអិលធីឌី លេខ ១០៦៤ កប/អក/វក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៣។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមរបស់ក្រុមហ៊ុន នីច ធី អីភែរីល (ខេមបូឌា) ខូអិលធីឌី ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ ២០១៣។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ៩១៥ កប/អក/វក/លកអ. ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៣។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ៩១៦ កប/អក/វក/លកអ. ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៣។

៣- សេចក្តីបញ្ជារបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០៣៥/១៣ កបអ. ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ ២០១៣។

៤- លិខិតលេខ ៩៤៨ កប/អក/វក/លកអ. ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៣ របស់លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល គោរពជូន ប្រធានសម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា ស្តីពីសំណើសុំផ្តល់របាយការណ៍ទាក់ទងនឹងស្ថានភាពកូដកម្មនៅក្រុមហ៊ុន នីចធី អីភែរីល។

THE ARBITRATION COUNCIL

**អង្គហេតុ**

- មិនមានការរកឃើញអង្គហេតុទាក់ទងទៅនឹងចំណុចបញ្ហាវិវាទនៅក្នុងរបាយការណ៍មិនសះជា ដែលនាយកដ្ឋានវិវាទការងារ បានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ ដោយសារក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនបានដំណើរការសវនាការ ។

**ហេតុផលនៃសេចក្តីសម្រេច ÷**

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើត្រូវបន្តនីតិវិធីអាជ្ញាកណ្តាលដែរ ឬទេ?

ប្រការ ២០ នៃប្រកាសលេខ ០៩៩ សកបយ របស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចែងថា ៖ "*ក្នុងអំឡុងពេលនៃដំណើរការរបស់ក្រុមអាជ្ញាកណ្តាល ភាគីវិវាទទាំងឡាយត្រូវផ្អាករាល់វិធានការវិវាទ ដូចជាកូដកម្ម ឬឡុកអៅ (ដូចមានចែងក្នុងមាត្រា ៣១៨ នៃច្បាប់ស្តីពីការងារ) ឬវិធានការដទៃទៀតដែលអាចធ្វើឱ្យស្ថានភាពវិវាទកាន់តែធ្ងន់ធ្ងរ ។ ភាគីទាំងនេះត្រូវតែចូលរួមគ្រប់កិច្ចប្រជុំទាំងឡាយដែលក្រុមអាជ្ញាកណ្តាលបានអញ្ជើញឱ្យចូលរួម* " ។

នៅក្នុងសេចក្តីបង្គាប់អាជ្ញាកណ្តាលមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបកស្រាយមាត្រានេះថា ក្រុមប្រឹក្សាអាជ្ញាកណ្តាល នឹងមិនបន្តដំណើរការអាជ្ញាកណ្តាលទេ នៅពេលណាដែលភាគីកម្មករនិយោជិតកំពុងធ្វើកូដកម្ម ។

ឧទាហរណ៍ នៅក្នុងសំណុំរឿងលេខ ០៤/០៤-អិម អេស អាយ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចេញសេចក្តីជូនដំណឹងមួយ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៤ ដែលកថាខ័ណ្ឌទី៤ នៃសេចក្តីជូនដំណឹងនេះ កំណត់ថា ៖

"*ដោយពិនិត្យឃើញថា ភាគីនៃវិវាទការងារនេះមិនមានសិទ្ធិធ្វើកូដកម្ម ក្នុងកំឡុងពេលនៃដំណើរការរបស់អាជ្ញាកណ្តាល ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនអាចធ្វើការដោះស្រាយ ឬក៏ចេញសេចក្តីបង្គាប់លើវិវាទការងាររួមនេះ ដែលបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលឡើយ ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចដោះស្រាយវិវាទការងាររួមនេះម្តងទៀតបាន នៅពេលណាដែលសហជីពកម្មករនិយោជិតទាំងអស់ឈប់ធ្វើកូដកម្ម* "។

ដូចគ្នាដែរ នៅក្នុងសំណុំរឿងលេខ ១៨/០៤-សណ្ឋាគារ (កាំបូឌីយ៉ាណា, រ៉ាហ្វែល ឡឺរ៉ូយ៉ាល់, រ៉ាហ្វល ប្រែនឌិ អង្គរ,សាន់វេ, អ៊ិនធើខនធីណេនថល និង សូហ្វីតែល អង្គរ) ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចេញសេចក្តីបញ្ជាទីពីរ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០០៤ ត្រង់ចំណុចទី៩ និងទី១១ នៃសេចក្តីបញ្ជានេះ ចែងដូចខាងក្រោម ៖

"*ចំណុចទី៩-ចាប់ពីថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០៤ តទៅ កម្មករនិយោជិតទាំងអស់ត្រូវបញ្ឈប់កូដកម្ម បាតុកម្ម ឬ ការរំខានណាមួយ នៅក្នុងបរិវេណសណ្ឋាគារនានា ដែលជាភាគីនៃវិវាទនេះ* " ។

"*ចំណុចទី ១១ - ក្រុមប្រឹក្សាអាជ្ញាកណ្តាលរក្សាសិទ្ធិក្នុងការបញ្ចប់ដំណើរការអាជ្ញាកណ្តាល ករណីដែលភាគីណាមួយបំពានប្រការណាមួយនៃសេចក្តីបញ្ជានេះ* " ។

នៅក្នុងសំណុំរឿងលេខ ៧៧/០៥-ប្រូង់កូ ទីតធីង ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចេញសេចក្តីបញ្ជាទី២ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០០៥ ហើយបានចែងនៅក្នុងចំណុចទី៤ ថា នៅក្នុងករណីដែលភាគីកម្មករនិយោជិតបន្តធ្វើកូដកម្ម ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងមិនដំណើរការដោះស្រាយវិវាទការងាររួមនេះទេ ។

THE ARBITRATION COUNCIL

នៅក្នុងសំណុំរឿងលេខ ១១០/១១-ស៊ីម៉ាណូ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏បានចេញសេចក្តីបង្គាប់មិនបន្តដំណើរការអាជ្ញាកណ្តាល ដោយមូលហេតុកម្មករនិយោជិត នៅតែបន្តធ្វើកូដកម្មក្នុងកំឡុងពេលដំណើរការនីតិវិធីរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលដែរ។

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏ឯកភាពតាមការសម្រេច របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនៗខាងលើដែរ ពោលគឺក្នុងករណីដែលភាគីកម្មករនិយោជិតនៅតែបន្តធ្វើកូដកម្ម មិនគោរពតាមសេចក្តីបញ្ជារបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងមិនដំណើរការដោះស្រាយវិវាទការងាររួមនេះទេ។

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចេញសេចក្តីបញ្ជា លេខ ០៣៥/១៣ កបអ. ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១៣ ដើម្បីបញ្ជាឱ្យកម្មករនិយោជិតដែលទាមទារនៅក្នុងសំណុំរឿងនេះ ផ្អាកជាបន្ទាន់នូវការធ្វើកូដកម្ម រហូតដល់នីតិវិធីនៃអាជ្ញាកណ្តាល ត្រូវបានបញ្ចប់សព្វគ្រប់តាមនីតិវិធីច្បាប់ ហើយកូដករទាំងអស់ត្រូវត្រឡប់ចូលធ្វើការវិញ ចាប់ពីព្រឹកថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១៣ តទៅ ទៅតាមវេនរបស់ខ្លួន។ ប៉ុន្តែ នៅថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១៣ កម្មករនិយោជិត នៅតែបន្តធ្វើកូដកម្ម ដោយមិនព្រមគោរពតាមសេចក្តីបញ្ជារបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៣៥/១៣ កបអ. ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១៣ ទេ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចមិនបន្តដំណើរការអាជ្ញាកណ្តាលក្នុងសំណុំរឿងនេះទេ។

យោងតាមអង្គហេតុ អង្គច្បាប់ និងហេតុផលដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ដូចតទៅ៖

## សម្រេច និង បង្គាប់

- មិនបន្តដំណើរការអាជ្ញាកណ្តាលក្នុងសំណុំរឿងលេខ ១៨២/១៣-នីច ធី អីភែរីល។

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

**អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក៖**

ឈ្មោះ៖ **កៅ ថាច**

ហត្ថលេខា៖ ----------------------------------------

**អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត៖**

ឈ្មោះ៖ **អន ណាន**

ហត្ថលេខា៖ ----------------------------------------

**ប្រធានក្រុមអាជ្ញាកណ្តាល៖**

ឈ្មោះ៖ **គង់ ផល្លះ**

ហត្ថលេខា៖ ----------------------------------------